Raung "Lauk krou Ek ei nẫung kaun seus bi neak"
R. le 2-9-53

# រឿង
# លោកគ្រូអ៊ិកអ៊ី
# នឹងកូនសិស្សពាណាក

RÉGIE DU DÉPÔT LÉGAL



ร-ร
168

# រឿង

# លោកគ្រូអ៊ិកអ៊ី

អ្នកនិពន្ធ

ករីសុខ - បឿ

រក្សាសិទ្ធិ

ការផ្សាយរបស់

ផ្ទះលេខ ៣, វិថីកាន់វូឡង់ហ្វូវែន ភ្នំពេញ

ព. ស. ២៤៩៦

គ. ស. ១៩៥៣

ARCHIVES NATIONALES
RÉGIE
DU
DÉPOT LÉGAL

ARCHIVES NATIONALES
COTE
B. 63. 649 86

# រឿងលោកគ្រូអ៊ិកអ៊ី

## នឹងកូនសិស្សពាក់នេះ

សុខ - បឿ ខ្ញុំបានរៀបរៀងដោយមានរឿងពីព្រេងនាយ ដែលបុរាណសម័យលោកបាននិយាយដំណាលតៗគ្នាមក កាលខ្ញុំដែលរៀបរៀងរឿងនេះ តាមលំដាប់ហូរហែតាំងពីខាងដើមដល់ខាងចុងតែម្ដង ៗ លោកគ្រូនេះកាលពីដើមមិនមែនឈ្មោះ អ៊ិកអ៊ីដូច្នេះទេ គឺឈ្មោះលោកតាសួស ដល់ទៅខាងចុងទើបបានពិតថា លោកគ្រូអ៊ិកអ៊ីដូច្នេះ សូមលោកអ្នកអានអ្នកស្ដាប់ទាំងឡាយ ចូលចិត្តពីហេតុខាងដើមដរាបដល់ខាងចុងដូចតទៅ ៗ

កវី សុខ បឿ

- រៀបរៀង -

មានសេចក្ដីដំណាលថា ក្នុងសម័យកាលដែលកន្លងទៅហើយនោះ មានលោកនេនមួយអង្គ អ្នកស្រុកគេតែងហៅថាលោកតាសួស ៗ នោះ ជានេនខ្ជិលខ្ជា យប់ៗដើរស្វែងក្នុងភូមិអ្នកស្រុក ដើម្បីលួចមាន់-អង្ករ-ត្រីសាប់ មាសប្រាក់កាក់ប្រាស យកទៅទិញស្រាយកមកផឹកស៊ីបាយយប់តែរឿយៗ មានមនុស្ស ៣ នាក់ រួមចូលផឹកស៊ីជាមួយផង លុះនៅយូរៗទៅ តាសួសរកប្រាក់នឹងទិញស្រាពុំបាន មួយទៀតគិតថា បើនៅយូរខ្លាចក្រែងអ្នកស្រុកគេដឹង ថាអញជាមនុស្សពុតអាក្រក់ គេនឹងបណ្ដេញអញចេញពីវត្តអារាម ទើបនិយាយពីគ្រោះគ្នានឹងមនុស្ស ៣ នាក់នោះថាយើងនៅក្នុងស្រុកធំនោះ ក្រប្រាក់ចាយណាស់ ឧបាសក ឧបាសិកាញោមវត្តនេះ គេពុំមានសទ្ធា ធ្វើបុណ្យធ្វើទាននឹងយើងទេ បើដូច្នោះគួរពួកយើងបបួលគ្នាចេញទៅស្រុកក្រៅ ដើរកៃខកុហកបញ្ឆោតអ្នកស្រុកស្រែចម្ការ ដោយឧបាយកលផ្សេងៗ គឺអញធ្វើជាលោកធុតង្គរុក្ខមូល ហៅឯង ៣ នាក់ធ្វើជាកូនសិស្សឧបដ្ឋាកដើរតាមក្រោយ ដើរនិយាយបញ្ចុះបញ្ចូលបបួលអ្នកព្រៃ ឲ្យគេជឿថាអញវិសេសខាងធុតង្គរុក្ខមូលគេនឹងនិមន្តធ្វើបុណ្យទាន បានចតុប្បច្ច័យហើយយើងកៃខ ទិញបាយទិញស្រាផឹកទៅតាមកាល ឯមនុស្សទាំង ៣ នាក់នោះ ក៏យល់ព្រមតាមលោកតាសួស ក៏ឲ្យឧបដ្ឋាករៀបចំត្រមុងកន្ទេល គ្រឿងបរិក្ខាររបស់

ធុតង្គ បានហើយទើបនាំមនុស្សទាំង ៣ នាក់នោះ ចេញចាកស្រុកក្រោម ទៅកាន់ស្រុកលើ ឯតាសួសក៏ក្លែងខ្លួនធ្វើជាលោកធុតង្គដោយត្រៃ ដល់វេលាព្រឹកក៏ចូលទៅបិណ្ឌបាតក្នុងស្រុកតាមលំដាប់ផ្លូវ ឯពួកឧបាសកឧបា-សិកានៅស្រុកក្រៅ កាលបើឃើញតាសួសនោះហើយ នឹកស្មានថាជាលោកសង្ឃធុតង្គរុក្ខមូលដោយសុចរិត ទើបនាំគ្នាដាក់បាត្រប្រគេនចតុប្ប-ច្ច័យផ្សេង ៗ អ្នកខ្លះនិមន្តឆាកមហាបង្សុកូល អ្នកខ្លះនិមន្តឆាន់ធ្វើបុណ្យផ្សេង ៗ តាមសទ្ធាអ្នកកាន់ព្រះពុទ្ធសាសនា តាសួសបានលាភសក្ការៈបរិបូណ៌ពោពាស ក៏ធ្វើជាសង្រួមឥន្ទ្រីយបែបពាងស្រគត់ស្រគំ រមទម្យពុំសូវនិយាយស្តីអ្វីប៉ុន្មានឡើយ ឯមនុស្ស ៣ នាក់នោះ តែដើរទៅដល់ទីណាក៏នាំគ្នានិយាយសរសើរអួតគុណតាសួស ប្រាប់អ្នកស្រុកនោះថា លោកគ្រូយើងនេះ លោកវិសេសខាងផ្លូវកង្ទពេកណាស់ ទាំងទឹកមន្តក៏ពូកែស័ក្តិ-សិទ្ធិ ចេះទាំងយិតមើលហួយមើលជោ ក៏ចុតឆាប់តែលោកថាអ្នកសន្តោស មិនមានសេចក្តីលោភទេ បើអ្នកណាត្រូវបិត្តលោក ៗ ក៏ប្រោសឲ្យបានសម្រេចប្រយោជន៍គ្រប់ប្រការ ពួកយើង ៣ នាក់នេះ ក៏ឧស្សាហ៍ដើរតាមលោកម្ល៉េះនេះ ព្រោះឃើញសិល្បវិជ្ជាការនេះមែនទែនណាស់ឯពួកមហាជនទាំងឡាយ កាលបើបានស្តាប់ពាក្យអ្នកទាំង ៣ ស្រដីអួតតាសួសដូច្នោះហើយក៏ជឿតាម ទើបនាំគ្នានិមន្តតាសួសសូត្របូជាព្រះ

គ្រោះខ្លះ សូមមន្តខ្លះ សូមខ្សែកខ្សែបង្កេះខ្លះ តាសួសបានលាភសក្ការៈ បរិបូណ៌ច្រើនឡើង ៗ ដោយពួកអ្នកស្រុកគោររាប់អាន តែដល់ពេលយប់ស្ងាត់ ចៅទាំង៣នាក់ក៏ទៅលួចទិញស្រា ទិញបាយមកលៀងគ្នាក្នុងព្រៃ



តាមវិស័យ សើចលេងសប្បាយរៀង ៗ ខ្លួន ។

ឯតាសួសនឹងអ្នក ៣ នាក់ ក៏ប្រព្រឹត្តអាការៈយ៉ាងនេះរៀង ៗ ទៅ

តាមផ្លូវ លុះថ្ងៃ ១ នោះ តាសួសនាំគ្នាទាំង ៣ នាក់ដើរទៅដល់ភូមិ ១ ទើបចូលទៅកាន់ភូមិនោះ ហើយទៅអង្គុយក្រោមម្លប់ដើមពោធិ៍ខាងត្បូងភូមិនោះ ឯចៅ ៣ នាក់ក៏នាំគ្នាចូលទៅក្នុងភូមិ និយាយឃោសនា ប្រាប់អ្នកស្រុកថា លោកពុទ្ធគ្រូមួយលោកនិមន្តមកគង់នៅខាងត្បូងភូមិនោះឯង បើបងប្អូនឬញាតិសន្តានព្រៀងលានណា មានប្រាថ្នាដោយការអ្វី ៗ សូមអញ្ជើញយកទឹកតែស្លាសេស្លាបារីទៅប្រគេនលោកចុះ លោកនិមន្តមកនេះ មិនមែនឥតប្រយោជន៍ទេ គឺនិមន្តមកប៉ងដើម្បីប្រោសសត្វបំបាត់សោកហើយ បើអស់លោកណាចង់បានខ្សែកខ្សែបង្កះ នឹងទឹកមន្តការពារពោគអាសន្នកម្មផ្សេង ៗ ក៏សូមអញ្ជើញទៅរកលោកដោយឆាប់ ៗ ចុះ ឯបណ្ដាមហាជនប្រុសស្រី នៅទីភូមិនោះលុះឮថា លោកពុទ្ធគ្រូមួយវិសេសមកដូច្នោះហើយ ខ្លះក៏បានស្លាបារី ខ្លះក៏បានទឹកក្ដៅត្រជាក់ នាំគ្នាទៅរកតាសួស ដល់ហើយក្រាបថ្វាយបង្គំសួរទទួលរាក់ទាក់ដោយអាមិសបដិសណ្ឋារៈគប់យ៉ាង ប្រគេនទឹកស្រង់ទឹកឆាន់ ស្លាម្លូកេសជ្ជៈតាមសព្វរៀង ៗ ខ្លួន ទើបសំពះសួរថា ៖

ព្រះករុណាម្ចាស់និមន្តមកពីស្រុកណា ?

ព្រះតេជព្រះគុណ !

តាសួសទទួលឆ្លើយថា ចំរើនពរអាត្មាភាពនេះនៅទីក្នុងទីក្រុងចេញ

មកធុតង្គរុក្ខមូលយូរខែយូរឆ្នាំហើយ អាត្មាភាពនៅតែក្នុងព្រៃមិនដែលចូលទៅកាន់ស្រុកភូមិណាទេញោម ! ទើបតែថ្ងៃនេះមានហេតុជាការមិនស្រួលនៅស្រុកភូមិញាតិញោមនេះ បានជាអាត្មាភាពខំឧស្សាហ៍និមន្តមកនេះ ឯពួកអ្នកស្រុកនោះ លុះឮតាសួសថាដូច្នោះហើយ ក៏កើតសេក្ដីសង្ស័យឡើងគ្រប់គ្នា ទើបនាំគ្នាសួរតបទៅវិញថា ៖

ករុណាម្ចាស់! បពិត្រព្រះគុណធ្ងន់ក្រៃ! មានពុទ្ធដិកានេះយល់ប្លែកពេកណាស់ ចុះលោកម្ចាស់យល់ហេតុភូមិយើងខ្ញុំនេះមិនស្រួលយ៉ាងណា ?

— ញាតិញោមអើយ ! អាត្មាភាពអង្គុយធម៌យប់មិញនេះ មានឃើញហេតុអន្តរាយ នឹងកើតមានដល់ញាតិញោមក្នុងភូមិនេះទាំងអស់គ្នា គឺអាត្មាភាពឃើញថាភូមិនេះនៅតែ ៧ ថ្ងៃទៀត នឹងមានអសនីបាត គឺអន្ទុះបាញ់មកត្រូវភូមិនេះដល់នូវសេចក្ដីវិនាសសាបសូន្យទាំងភូមិជាម្ដង! អាត្មាភាពគិតនឹកអាណិតដល់ញាតិញោមទាំងអស់គ្នាណាស់ ! បានជាខំឧស្សាហ៍មកនេះ ប្រាថ្នានឹងប្រាប់សេចក្ដីនោះឲ្យញាតិញោមបានដឹងខ្លួនជាមុន ថាបើញាតិញោមឯណាចង់ឲ្យរួចពីកាឲ្យកណ្ដីសេចក្ដីវិនាសនោះ ត្រូវតែរុះរើផ្ទះសំបែងចេញអំពីភូមិចាស់ ទៅតាំងនៅភូមិក្រៅជាថ្មីម្ដងទៀត នោះទើបរួចភ័យអំពីអសនីបាតនោះបាន ឯបណ្ដាមហាជនទាំងឡាយ

នោះ លុះពួកតាស្មូសថាដូច្នោះហើយ ក៏កើតសេចក្តីភិតភ័យតាំងអស់គ្នាទើបតបវិញថា:

សូមទានករុណាម្ចាស់ ! បើដូច្នេះ សេចក្តីវិនាសនោះ នឹងមានដល់ពួកយើងខ្ញុំហើយឬ ? តែថាឲ្យពួកយើងខ្ញុំរុះរើផ្ទះសំបែងនោះ ចេញអំពីភូមិនោះទៅតាំងនៅភូមិជាថ្មីទៀត ជាការលំបាកពន់ពេកណាស់បើដូច្នោះ សូមករុណាម្ចាស់ នឹងមានឧបាយកលល្អឧបទេសកែខៃសេចក្តីអន្តរាយអំពីអន្ទះនោះជាបានខ្លះឬទេ ?

— ឱញាតិញោមអើយ ! បង់គិតកែខៃឧបទេសនោះ ប្រហែលជាបានមើលទៅ ! ចាំអាត្មាភាពអង្គុយធម្មិសាកមើលសិន ថាហើយតាស្មូសក៏តាំងអុជទៀនធូបហើយតាំងសមាធិ អង្គុយធ្មេចភ្នែកបន្តិចបើកភ្នែកឡើងថា បានញោម ! មិនអីទេ តែញាតិញោមត្រូវខាតដើមទុនខ្លះទើបអាចធ្វើបាន .....

— ករុណាម្ចាស់មិនអីទេ ពោះបង់ខាតធនធានប៉ុន្មានៗ ក៏មិនថាទេធ្វើម្តេចឯងដល់សេចក្តីវិនាសហើយ សូមនិមន្តលោកគ្រូម្ចាស់បង្គាប់មកចុះ

— ឱ ! ញាតិញោមអើយ អាត្មានេះជាសង្ឃផងនឹងបង្គាប់បញ្ជូទៅ ក៏ហាក់ដូចជាមិនគួរនឹងកេឲឯងទៅជាសមណ:នោះសោះ ដ្បិតភ្លើងអន្ទះនោះ តាមបាលីថា អសនី គឺថា អសុភ ប្រែថា យក្ខខ្មោចៗ

នោះវាគាប់ចិត្តតែនឹងស្រាបាយ សាច់ញាំក្ងាមាន់ស្ងោរ រៀបបូជាពលិការរ៉ា ហេតុនោះបានជាសក្តិពល់ណាស់ ព្រោះឯងជាលោកសន្យ...

– ករុណាម្ចាស់ កុំព្រួយព្រះទ័យឡើយ និមន្តបង្គាប់មកចុះ ពួកយើងខ្ញុំនឹងធ្វើតាម

– ឱ! ញាតិញោមអើយ... ត្រូវធ្វើរោងពិធី ១ ខ្នងនៅក្រៅភូមិ ហើយឲ្យធ្វើជាពជវតិ ទង់ ឆត្រ ស្វាធមិ បាយសី ជម ចារ គ្រឿងបំភាបបន្ថែមផ្សេងៗ យកទៅតាំងនៅរោងពិធី...

មនុស្សទាំងឡាយ ក៏នាំគ្នាធ្វើតាមពាក្យតាស្លួសនោះសព្វគ្រប់ប្រការ ឯតាស្លួសក៏នាំគ្នាទាំង ៣ នាក់ចូលទៅក្នុងរោង ហើយយកអំបោះ ចងព័ទ្ធសីមា ៧ ជាន់ ហើយប្រាប់អ្នកស្រុកថា ញាតិញោមទាំងអស់នេះ សុទ្ធសឹងតែមនុស្សមានគ្រោះធំ ត្រូវតែនៅក្រៅរោងពិធីនេះ តាស្លួសថាហើយ ទើបសរសេរសំបុត្របិទនៅមាត់ទ្វារនោះ ថា៖

– កុំឲ្យនរណាចូលមកក្នុងរោងពិធីនេះឡើយ ថាបើនរណាអាចហ៊ានកាត់អំបោះសីមាកន្លងចូលមកក្នុងរោងពិធីនេះហើយ អ្នកនោះនឹងទៅជាឆ្កួតឈឺស្លាប់កើតវិបត្តិផ្សេងៗ បណ្ដាអ្នកស្រុកទាំងនោះក៏ធ្វើតាមតាស្លួសហាមទាំងអស់ នាំគ្នាហាមកូនចៅក្មេងតូចធំ កុំឲ្យចូលទៅក្នុងរោងពិធីនោះៗ

ឯតាស្លួសបានឱកាសស្ងាត់ហើយ ក៏នាំគ្នាទាំង ៣ នាក់សុំបាយផឹក

ស្រាតាមអំពើពុតអាក្រក់ លុះស្រវឹងស្រាខ្លាំងក៏តាំងនិយាយគោកគាក ៗ ប្រកែកគ្នាទៅវិញទៅមកគឹកកងរំពងក្នុងរោងនោះ លុះនៅដល់បាន ២-៣ ថ្ងៃ មានកុមារម្នាក់អាយុ ១៤ ឆ្នាំ ឈ្មោះចៅសេក ក្មេងនោះវាទៅឃ្វាល ក្របីនៅវាលស្រែ ដល់ពេលថ្ងៃល្ងាចត្រជាក់ ចៅសេកវាដេញក្របី ទៅផ្ទះ បរទៅខាងរោងពិធីនោះ បានឮសំឡេងអ្នកទាំង ៤ នាក់ ផឹក ស៊ីប្រកែកគ្នាគោកគាកដូច្នោះហើយ ចៅសេកគិតថា សំឡេងយ៉ាងនេះ ទំនងជាមនុស្សស្រវឹងស្រា យ៉ាងជាលោកសង្ឃនោះផឹកស្រាទេដឹង បើ ដូច្នេះគួរអញទៅលបមើលអេះ ដើម្បីបញ្ជាក់ការនោះឲ្យជាក់ច្បាស់សិន ទោះវាធ្លុតប្តូឈើទាបយ៉ាងណាក៏តាមចុះ អញប្រថុយលមើល គិត ហើយ ក៏ដើរលបចូលទៅដល់ប្របជញ្ជាំងរោង ហើយលួចបើកស្លឹក ត្នោតដែលបាំងនោះគន់មើលទៅក្នុងរោង ក៏ឃើញតាដែង ៤ នាក់នោះ វាអង្គុយជុំគ្នា ស៊ីបាយផឹកស្រាដោយអំពើពុតអាក្រក់ ចៅសេកឃើញ ហើយក៏នឹកថា យី ! តាដែងគស់នេះ ផឹកស្រាស៊ីបាយល្ងាចទេតើ ! ពុទ្ធោ ៗ ! ធម្មោ ៗ ! សង្ឃោ ៗ ! ទុ ! ម៉ែឪអញទៅរៀនពួកនេះធ្វើ ទេទេ ទាំងអ្នកស្រុកក៏ជឿចុះចូលវា ឲ្យវាបញ្ឆោតអស់ទាំងអ្នកស្រុកទៅ ហើយ បើដូច្នោះគួរអញទៅប្រាប់ម៉ែឪអញឲ្យគាត់បានដឹងផង គិត ហើយក៏ដើរថយចេញមកមា រត់ត្រង់ទៅផ្ទះ បានឃើញម្តាយនៅលើផ្ទះ

ចៅសេកក៏ស្រែកប្រាប់ទៅថា ម៉ែៗ លោកអ្នកមានគុណធ្ងន់ក្រៃ! ម៉ែឯងទៅជឿអីលោកសង្ឃពុតគ្គិនោះ មិនពិតជាលោកសង្ឃល្អទេ វាក្លែងក្លាយទេម៉ែ ខ្ញុំបានឃើញវាផឹកស្រាស៊ីបាយល្ងាចអំបាញ់មិញនេះឯងៗ

ឯនាងជាម្ដាយបានឮពាក្យកូនប្រាប់ដូច្នោះហើយ ក៏ពុំមានសតិសម្បជញ្ញៈ នឹងត្រិះរិះឲ្យច្បាស់លាស់ ដោយជឿពាក្យលោកតាសួសថា នរណាគាត់សីមាចូលក្នុងរោងពិធីលោក អ្នកនោះនឹងឆ្កួតប្រាកដ ទើបកើតភិតភ័យតក្កមាហើយសួរថា កូន! កូនៗឯងចូលទៅក្នុងរោងពិធីលោកឬអី? កូនឆ្លើយថា បាទ បាទខ្ញុំលបលួចចូលទៅឃើញ វាកំពុងតែផឹកស៊ីទាំង ៤ នាក់ណាម៉ែ ម្ដាយថា ឱ! កូនអើយលោកបានហាមប្រាមទាំងអស់គ្នា ថាកុំឲ្យនរណាចូលទៅក្នុងរោងពិធីលោក ឥឡូវកូនឯងចូលទៅនោះ ត្រូវដូចពាក្យលោកថា អ្នកណាចូលហើយ អ្នកនោះនឹងឆ្កួតមិនខាន ឥឡូវកូនឯងឆ្កួតហើយតើកូន គួរអីទៅថាលោកសង្ឃផឹកស្រានោះ លោកជាអ្នកដើរធុតង្គរុក្ខមូលវិសេសណាស់ ចៅសេកប្រកែកថា ម៉ែឯងមិនជឿខ្ញុំទេឬ? ខ្ញុំបានឃើញច្បាស់នឹងភ្នែកហើយ អាផេងទាំង ៤ នាក់នោះវាមកក្លែងបញ្ឆោតគេយកលាភទេ អ្នកណាទៅជឿវាគង់នឹងខូចខ្លួនមិនខាន ឯនាងម្ដាយមិនស្ដាប់ បេះតែថាអាឯងទៅចូលក្នុងសីមាលោក វាឆ្កួតមែនហើយ ឯបណ្ដាពួកញាតិនៅជិតខាង បានឮចៅសេកនឹងម្ដាយប្រកែក

គ្នាដូច្នោះហើយ សឹងនោះឡើងទៅសួរថា ម្តេចចៅសេកវាទៅចូលក្នុងសីមាលោកនោះឬអី? នាងម្តាយក៏ប្រាប់ទៅថា អើឯងអើយ វាចូលទៅក្នុងសីមាលោក ឥឡូវវាឆ្កួតណាស់ ទៅតាំងតែជេរលោកសង្ឃនោះផ្សេង ៗ

ឯពួកញាតិ ក៏តាំងស្តីបន្ទោសចៅសេកថាឆ្កួតមែនហើយ ធ្វើម្តេចនឹងរកគ្រូឯណាទីងមើលបាន ឯចៅសេកឮពួកញាតិគេស្តីបន្ទោសដូច្នោះហើយ ក៏ខឹងណាស់ តាំងជេរជាសពាសទៅ ដល់ប្រកែកនឹងគេមិនឈ្នះ វាក៏យំស្រែកផងព្រោះដោយសោកក្នុង ឯពួកញាតិក៏នៅតែជឿថាចៅសេកឆ្កួតមែន គឺពីដើមគ្រាន់តែជាលោកសង្ឃផឹកស្រា ឥឡូវខ្លាំងតាំងយំជេរគេ ជេរឯងតែម្តាស មិនស្គាល់ចាស់ក្មេងផង ឯនាងជាម្តាយនោះ ក៏ភិតភ័យខ្លាំង ទើបរត់ទៅឯកោនពីធីលោកតាសួស ដល់ហើយស្រែកហៅទៅថា៖

ឱ! ករុណាម្ចាស់ សូមមេត្តាប្រោសសត្វបំបាត់សោក! សូមទានទឹកមន្ត! ចេញមកខាងក្រៅកេងសិន ដ្បិតសត្វកើតវិបត្តិហើយ ព្រះគុណម្ចាស់ ឯតាសួសឮនាងសីកាទឹមន្តចេញដូច្នោះ ក៏ស្ទុះប្រញាជូតមាត់ជូតកស្អាកហើយ តាំងគ្រងចីពរជាបរិមណ្ឌល ពាក់ផ្គុំកាន់ឈើច្រត់ ដើរលប ៗចេញមកខាងក្រៅហើយសួរថាកើតអីញោម បានជាភិតភ័យរលះរលាំងយ៉ាងនេះ? នាងសីកានោះអង្គុយលុតជង្គង់ប្រណម្យដៃ ទូលថាករុណាម្ចាស់!

ឥឡូវនេះចៅសេកកូនខ្ញុំករុណាវាចូលមកក្នុងសីមាលោកម្ចាស់ ឥឡូវកើតទៅជាឆ្កួតពុំដឹងអ្វីសោះ ចេះតែយំស្រែក ជេរគេឯងពាសទៅជេរត្រូវទាំងលោកម្ចាស់ផង ។

តាសួរឆ្លើយថា អើញោម អាចក្តីបានហាមហើយ ថាកុំឲ្យប្រហែសឲ្យហាមកូនហាមចៅកុំឲ្យវាចូលមកក្នុងសីមាពិធីនេះ ក្រែងវាកើតហេតុឥឡូវមែន ៗ ដូចពាក្យអាចក្តីថា ចុះឥឡូវនេះវានៅឯណា កូនញោមនោះ?

— ករុណាម្ចាស់ វានៅឯផ្ទះខ្ញុំករុណាឯនោះ

— អើបើ ដូច្នោះ ញោមទៅនាំខ្លួនវាមកឯរោងពិធីនេះ អាចក្តីនឹងមើលរោគឆ្កួតនោះណាញោម នែញោមពាក្យចាស់លោកថា:

បន្លាមុត គេងយកបន្លាដូស . . .

ទឹកចូលត្រចៀក គេងយកទឹកចាក់ . . .

ត្រូវកំចាត់សត្រូវដោយសត្រូវ

ឲ្យទៀតដែលត្រូវដល់ចិត្តវា

ដូចបន្លាដែលមុតក្នុងបាទា

យកបន្លាដូចគ្នា ដូសទើបបាន ។

រោគឆ្កួតកើតមកពីរោងពិធីនេះឯង គេងញោមយកមករក្សាឯរោងពិធីនេះទើបជាសះស្បើយទៅបាន ឯនាងសិកានោះក៏សំពះលាតាសួស វិលទៅ

ពឹងបងប្អូនប្រុសៗ ៣-៤ នាក់ឲ្យជួយចាប់យកខ្លួនចៅសេក មកប្រគល់ឲ្យតាស្លួស ឯចៅសេកនោះត្រូវគេមកចាប់ដឹកនាំទៅដូច្នេះ ក៏ដឹងតែតែខឹងនឹងពួកញាតិតាំងបម្រះនទៀលជេរគេជេរឯង ហើយយំស្រែកទៅតាមតាសាក្រូនតែជនទំពុំបាននឹងកំលាំងមនុស្សចាស់ៗ គេក៏នាំគ្នាចាប់សែងពនាំទៅដល់រោងពិធីនោះ ឯតាស្លួសក៏បបួលគ្នាទាំង ៣ នាក់ចេញមកខាងក្រៅរោង ហើយទទួលយកចៅសេកចូលទៅក្នុងរោងតាស្លួប ១ ប្រាប់ទៅថា: ញោមទាំងអស់គ្នាស្ទូវតែជាអ្នកមានគ្រោះថ្នាក់នឹងនៅជិតរោងពិធីពុំបាន ក្រែងខ្មោចព្រាយអសនីនោះវាចូលរូបអាត្មានឹងស្រោចទឹកមន្តចៅសេកហើយ ខ្មោចដែលនៅក្នុងរូបចៅសេកវានឹងស្រែកជាខ្លាំងពុំខាន បើដូច្នេះចូលញាតិញោមទាំងអស់គ្នាចៀសចេញទៅផ្ទះវិញឲ្យឆាប់ៗ កុំនៅយូរ ក្រែងខ្មោចវាចូល ឯរូបចៅសេកនេះមិនអីទេ តែស្អែកខានស្អែកគង់នឹងជាពុំខាន ឯពួកញាតិចៅសេក ឮតាស្លួសថាដូច្នេះហើយ ក៏នាំគ្នាសំពះលាតាស្លួសវិលទៅផ្ទះទីទៃៗទៅ ឯតាស្លួសចូលទៅក្នុងរោងពិធី ហើយឲ្យគ្នា ៣ នាក់នោះចងចៅសេកភ្ជាប់នឹងសសររោង តាំងការរំពាត់ផ្ដៅម្នាក់មួយៗ គ្រប់ទាំង៤នាក់ ហើយកំហែងសួរចៅសេកថា: អើអាសេកអាឯងថា ឃើញពួកអញស៊ីបាយផឹកស្រាមែនឬដូចម្ដេច ?

ចៅសោកឆ្លើយថា អើមែនខ្ញុំឃើញលោកតាឯង ផឹកស្រា ស៊ីបាយល្ងាច ប្រាកដទាំង ៤ នាក់មែន ពួកទាំងនោះក៏កើតកោសោ ហើយវាយចៅសោក ៤-៥ រំពាត់ ចៅសោកក៏ស្រែកយំដោយសំឡេងខ្លាំង ទាំង ៤ នាក់



ក៏សួរសោកទៀតថា ដូចម្ដេចអាសោកអាឯង ថាពួកយើងផឹកស្រាមែន ឬ ដូចម្ដេច ?

— អើ អាឯងផឹកស្រាមែន អញឃើញច្បាស់នឹងភ្នែកអញហើយ អា ៤ នាក់ក៏រឹតតែវាយខ្លាំងឡើង ៗ លើសមុន ចៅសេកបានដល់នូវសេចក្ដីទុក្ខវេទនាឈឺចាប់ពន់ពេកណាស់ ដល់ក្រោយទើបគិតថា ឱ ! អញនេះ ជាមនុស្សក្មេងម្នាក់ឯង គេឆ្កួតពេញទាំងស្រុកទៅហើយ តែឯងមិនធ្វើឆ្កួតតាមគេនោះ អាដែងពួកនេះ វាមុខជាវាយអញដល់នូវសេចក្ដីស្លាប់ពុំខានឡើយ ។

ណ្ហើយចុះគាត់ធ្វើជាឆ្កួតតាមវាទៅចុះទើបរក្សាខ្លួនសុខបាន ចៅសេកគិតដូច្នោះហើយទើបលើកដៃសំពះតាសួស ហើយសារសព្វប្រាប់ទៅថា:

ករុណាម្ចាស់ ខ្ញុំករុណានេះឆ្កួតពិតមែនហើយសូមទានប្រោសអត់ទោសខ្ញុំ ៗ ឆ្កួតមិនដឹងខ្លួនមិនដឹងប្រាណទេព្រះគុណ បានជាថាព្រះគុណផឹកស្រានោះ គឺព្រះគុណពុំមែនឆាន់ស្រាទេ ខ្ញុំឆ្កួតមែនហើយ ឥឡូវខ្ញុំដឹងខ្លួនជាសះស្បើយហើយ រាងចាលហើយ ពីនេះទៅទៀតខ្ញុំពុំថាព្រះគុណផឹកស្រាទេទាន

— អើបើ ឯងលែងថាអញផឹកស្រារាងចាលហើយ អញក៏លែងវាយឯង ៗ តែត្រឹមនេះ ករុណា ខ្ញុំករុណាលែងថា ព្រះគុណឆាន់ស្រាទៀតហើយ អំពីថ្ងៃនេះតទៅបើដូច្នោះមែន អញក៏លែងវាយឯងដែរ បើឯងនៅតែថាអញ ៗ ក៏វាយឯងទាល់តែស្លាប់ ថាហើយតាសួស ក៏ឲ្យ

ស្រាយចំណងចៅសេកឃាត់ខាំងចៅសេកមិនឲ្យចេញទៅខាងក្រៅរោងពិធី ឯចៅសេកសោតទាល់ចំណោះ ក៏នៅបំរើអា ៤ នាក់នោះទៅតាមអធ្យាស្រ័យវា លុះថ្ងៃគំរប់ ៧ ជាពេលយប់ស្ងាត់ ចៅសេកដេកលក់ទៅអាដែង ៤ នាក់នោះ តាំងរើគ្រឿងពិធីយកប្រាក់សំពត់ផ្តិល ជើងពានវេចជាសម្ពាយហើយនាំគ្នាលបរត់ចេញចាកស្រុកនោះ ទៅកាន់ស្រុកឯទៀតទៅ លុះដល់វេលាព្រឹកចៅសេកភ្ញាក់ឡើង ស្រាប់តែស្ងាត់ឈឹងចាំងរោងមើលទៅគ្រឿងតាំងពិធីនោះក៏បាត់អស់រលីងគ្មានសល់ដល់តិចតួចឡើយ ចៅសេកក៏ដឹងថាតាសួស លួចរបស់ទ្រព្យរត់ទៅអស់ហើយ ទើបចៅសេកដើរចេញចាករោង ចូលទៅផ្ទះខ្លួន ឯបណ្តាញាតិមិត្រឃើញចៅសេកដើរមកផ្ទះហើយ ក៏សួរថា ដូចម្តេចទៅជីសេកអើយ ! ពេលនោះបានស្រាកស្រាលផ្លូវខ្លួនប្រាណខ្លះហើយឬដូចម្តេចទៅ ?

ចៅសេកក៏តបថា នៅឡើយទេ តែថា ឥឡូវនេះ អំពើចិត្តនោះវានៅលើអ្នកស្រុកទាំងអស់គ្នា អើឯង ៗ ជាសោះគេឆ្កួតពេញទាំងស្រុក ក៏ត្រឡប់ថាឯងឆ្កួតវិញ អើមិន មារ យាយតា ទាំងអស់គ្នាទៅជឿអាដែង ៤ នាក់នោះទុកជាគ្រូ ថាលោកពុទ្ធគ្រូមូលវិសេសណាស់ ឥឡូវគ្រឿងប្រដាប់ដែលតាំងពិធីពីការនោះ លោកពុទ្ធគ្រូទោះបន្ទុំតាកយកទៅអស់ហើយ ថាហើយចៅសេកក៏ដើរដម្រង់ទៅផ្ទះទៅ ។

ឯបណ្ដាអ្នកស្រុកបានឮចៅសេកថាដូច្នោះហើយ ខ្លះក៏សង្ស័យថា ក្រែងពិតដូចពាក្យចៅសេកថាឬ ? ទើបនាំគ្នាទៅឯរោងពិធី ស្រាប់តែឃើញស្ងាត់ឈឹងស្ងៀម ក៏ចូលទៅក្នុងរោងឃើញរបស់ទ្រព្យខ្លួននោះវិនាសអស់ទៅដោយដៃមនុស្សបម្រើទាំង ៤ នាក់ដូច្នោះហើយ ទើបនាំគ្នាមកកាន់ផ្ទះរៀងៗខ្លួនវិញ កើតវិប្បដិសារីរលឹកទោសខ្លួនឃើញថាជាមនុស្សឥតបញ្ញា ឆ្កួតអស់ទាំងស្រុក គ្មានអ្នកណាជាសោះ ចៅសេកគ្នាជាសោះ ទៅថាគ្នាឆ្កួត ឱ! ពុទ្ធោ អរហំ ក្បាលអាំងកន្ទុយស្វារ អាចម៍គណ្ដុរកន្ទុះកញ្ជ្រោ ។

និទានពីរឿងតាស្លូសអស់សេចក្ដីតែប៉ុណ្ណេះ; ចាប់តាំងពីនេះទៅទៀត និយាយពីឈ្មោះលោកគ្រូអ៊ិកអ៊ី ៗ នេះកាលពីដើមឈ្មោះលោកតាស្លូស ដល់មករឿងខាងចុងទើបគេឲ្យឈ្មោះលោកគ្រូអ៊ិកអ៊ីទៅវិញ សូមលោកអ្នកអាន អ្នកស្ដាប់ទាំងឡាយ គួរចូលចិត្តតាមរឿងខាងក្រោមដូចតទៅនេះ!

## តត្រាយំ វគ្គ =

រឿងរ៉ាវនេះ មានក្នុងផ្ទៃនោះថាលោកតាស្លូសនឹងសិស្ស ៣ នាក់នាំគ្នារត់ចេញពីទីនោះទៅ បានទៅដល់ភូមិ ១ ឆ្ងាយរំលងស្រុក ១ ស្រុក ២ ជិតដល់ទៅទីក្រុង តាស្លូសនៅយូរ ៗ ទៅ រកវត្តអ្នកបរិភោគពុំសូវបាន

ពេញលេញដូចក្នុងពេលមុន ទើបបង្គាប់កូនសិស្ស ៣ នាក់ថា៖ ម្នាល អា ៣ នាក់! អាឯងចូរធ្វើតាមពាក្យអញ ទើបបានវត្ថុស៊ីចាយសប្បាយចិត្ត មើលទៅពួកយើង បើគាន់តែងមិនបែបហ្នឹង មុខជាស្លុតពោះពុំខាន ដូចពាក្យយើងថា៖

វិន័យក្រៀមផ្អាក តិរេកស្អួតពោះ វិន័យគ្មានយស ប៉ោងពោះ តិរេក ។

បដិសំខាយោនិសោ ពូតពម បាយកកសម្ផុម ត្រីប្រាខ្លាញ់ខាប់

លើកពមប្រញាប់ តតិយម្បិ ។

ពួកយើងកុំបាច់គិតអ្វីច្រើន គិតតែពីស៊ីដេក ៗ កុំបាច់គិតខ្វល់ខ្វាយ ពួកយើងថាម៉ាយរស់ដោយមានក្បួន អ្នកមានព្យាយាមប្រាជ្ញមាំមួន បានបេះចាំក្បួន បានជាការអ្វី?... ៗ

បើដូច្នេះ ចូរឯងទាំង ៣ នាក់ធ្វើតាមពាក្យអញ

— ករុណាលោកគ្រូ មិនអីទេ .....

ឯងទាំង ៣ នាក់ ត្រូវទៅលបមើល នង្គ័ល របស់ ក្របី-គោគេ ដែលគេយកទៅទុកដាក់នៅវាលស្រែ ឯងទាំងអស់គ្នា ចូរទៅយករបស់ទាំងនោះ យកទៅលាក់ឲ្យបាត់ ឲ្យឆ្ងាយពីកន្លែងបន្តិចទៅ ហើយឯងទាំងអស់គ្នា មកប្រាប់អញឲ្យដឹងសព្វគ្រប់អស់ហើយ ឯងដើរទៅនិយាយអួត

ការប្រាប់អ្នកស្រុកឲ្យគេជឿ ហើយគេមករកអញទាយ កាលបើអញទាយទៅត្រូវ គេនឹងយកបាយសម្លុយកាក់មកបូជាអញហើយ យើងទាំងអស់គ្នា មុខជាបរិបូណ៌គ្រប់គ្រាន់ ស៊ីបាយសប្បាយកាយសប្បាយចិត្តពុំខាន កូនសិស្សតាំងធ្វើតាមពាក្យលោកតាសួស ឯអ្នកស្រុកស្រែ ខ្លះបាត់ដង្កូល រនាស់ ខ្លះបាត់គោ ខ្លះបាត់ក្របី ដល់ឮថាលោកតាសួសល្បីឈ្មោះពូកែខាងទាយ ពួកគេទាំងនោះ ចូលមករកលោកតាសួសឲ្យទំនាយឲ្យតាមរបស់រៀង ៗ ខ្លួន

ឯតាសួសក៏ចាប់យកដីស ទឹងក្តារឈ្នួន មកគូសខ្វែងចុះ ខ្វែងឡើងរួចហើយ ទើបកាប់លេខថា ៖

ប៉កអ៊ិកប៉កអឺ ជើងក្តាមប្រាំបី
បេកជុតដំឡូងស្ងោរ...
អត្តខ្លួនប្រាណ ទៅណាមិនបាន
នៅក្នុងទីនោះ.....
អត្តខ្លួនអាត្មា ពុំបាត់ទៅណា
នឹងរកឃើញវិញ..... ។

ទើបទំនាយថា : ញោម គោនឹងក្របី ញោមឯងរកមើលក្នុងព្រៃថ្កុកត្រពាំងខាងឡិចស្រែ ឃើញហើយមិនបាត់ទេ ឯនង្គ័លនឹងរនាស់ នៅក្នុងត្រពាំង

ទឹកនោះដែរ ចុះពវរកមើលកន្ទទឹកទៅឃើញហើយ ។

ពួកគេទាំងអស់ ក៏ទៅរកមើលតាមពាក្យលោកតាសួស ក៏ឃើញពិតប្រាកដមែន គេក៏ជឿតាមស្នងចិត្តគំនិតទាំងអស់គ្នា ឯកូនសិស្ស ៣ នាក់ តាំងពីថ្ងៃនោះមក បេះតែដើរស្ទង់រកលបលួចលាក់ទ្រព្យរបស់អ្នកស្រុក ឲ្យគេមករកលោកតាសួស ឯតាសួសបេះតែទំនាយទៅត្រូវចំទាំងអស់ឥតមានខុស ឈ្មោះលោកតាសួសក៏ល្បីឮសុសសាយពេញទាំងស្រុក កាលថ្ងៃ១នោះ ពួកអ្នកស្រុកគេចង់ដឹងវិជ្ជាការលោកតាសួស គេគិតគ្នាមករកលោកឲ្យទំនាយឲ្យ ថាថ្ងៃស្អែកនេះ ភ្លៀងឬមិនភ្លៀង គេចង់ដឹងគេសាកល្បងមើល ទើបចូលមករកតាសួសឲ្យទំនាយឲ្យ ឯតាសួសកាលបើអ្នកស្រុកគេមករកឲ្យទំនាយពីភ្លៀងមិនភ្លៀងដូច្នោះ ក៏ទាល់គំនិតគិតមិនលេច ទើបប្រាប់គេថា ណ្ហើយញោមពេលនេះអាត្មា ហាក់ដូចជាពុំស្រួលកាយសប្បាយចិត្តសោះ ចាំពេលក្រោយសិន ម្យ៉ាងទៀតការទំនាយពីភ្លៀងមិនភ្លៀងនេះ ជាការលំបាកណាស់ លុះណាតែគិតផ្ចាញ់តាមលេខនេះសាចុះសាឡើង ចំនួន ១ យប់ ទើបអាត្មាហ៊ានទាយទៅប្រហែលជាត្រូវខ្លះ បើដូច្នោះ បូរញាតិញោមទាំងអស់គ្នាអញ្ជើញទៅផ្ទះសិនចុះ ចាំថ្ងៃក្រោយ ៗ ពួកអ្នកស្រុកក៏ធ្វើតាមពុំហ៊ានរំលងទទឹងឡើយ ។

ឯតាសួសទីងសិស្ស ៣ នាក់អង្គុយជុំគ្នាស៊ីផឹកពុំបានសប្បាយដូចពេលមុនឡើយ ព្រោះកើតទុក្ខ ជំនុំជម្រះគ្នាពីទំនាយភ្លៀងឬមិនភ្លៀង អ្នកទាំង៤ក៏ពាល់គំនិតគិតមិនលេច មុជមិនជ្រៅ ទៅមិនឆ្ងាយ កើតចិត្តក្ដៅក្រហាយ ទើបនាំគ្នារត់ចេញទៅទាំងយប់ ពេលដែលលបរត់ចេញទៅនោះគ្រាន់តែដើរទេ តែដើរបែបលឿនរហ័ស ព្រោះភិតភ័យតែរៀងៗខ្លួនៗ ចួនជាពេលនោះ ពួកអ្នកស្រុកផ្ដើលគោឡានទីងពួកចោរព្រៃ រាចូលមកប្លន់អ្នកស្រុកយកគោក្របី ឯតាសួសទីងសិស្ស ៣ នាក់ព្រួសស្រ័ពខ្លាំង



ដូច្នោះ រឹងរិតតែភ័យខ្លាំងឡើង ឯសិស្ស ៣ នាក់រត់ប្រាយទៅពោល

តាសួស ៗ រត់ទៅតាមក្រោយពុំសូវលឿន ព្រោះខ្លួនចាស់ដកជួលប្រញាប់ប្រងិលរត់បន្តិចទៅដល់ត្រពាំងទឹក លោកតាសួសក៏ចាក់ទឹងល្វៃផ្លូលដេកនៅក្បែរត្រពាំងទឹក ឯត្រពាំងទឹកនោះមានសត្វកង្កែបហ៊ុង វាយំឆ្លើយឆ្លងគ្នា តាសួសគិតថា អើអញ ប្រហែលជារួចខ្លួនមើលទៅ ស្អែកនេះពិតជាភ្លៀងហើយ បានជាសត្វទាំងអស់នេះ វាយំឆ្លើយឆ្លងគ្នា បើដូច្នោះអញគិតត្រឡប់ទៅវិញទើបស្រែកប្រកូកហៅសិស្ស ៣ នាក់ឲ្យត្រឡប់វិលវិញ តាសួសនឹងសិស្ស ៣ នាក់នាំគ្នាមកនៅទីកន្លែងដើមវិញ ពុំមានអ្នកណាដឹងសោះ ព្រោះយប់ស្ងាត់ណាស់ មកដល់ហើយតាសួសប្រើសិស្ស ៣ នាក់ឲ្យទៅដាស់អ្នកស្រុកទាំងយប់មកកុំឲ្យខាន តែខានអាចក្តីលែងទំនាយឲ្យទៀតហើយឯសិស្ស ៣ នាក់ក៏ធ្វើតាម ទៅហៅអ្នកស្រុក ៗ ក៏បបួលគ្នីគ្នាមកចំនួន ២០៣០ នាក់មកដល់អង្គុយនិយាយរៀបរាប់តាមហេតុដើម តាសួសទាញដីសក្តារឈ្នួនមកខ្វែងចុះឡើង រៀបរាប់ដូចពេលមុនទើបទំនាយថា នែញាតិញោម ! ទាំងអស់គ្នា ស្អែកនេះប្រុងប្រយ័ត្នឲ្យមែនមែន ព្រោះមានភ្លៀងធ្លាក់ជាច្រើនមេមកលើស្រុកភូមិញាតិញោមបើរៀបចំរបស់អ្វី ៗ ក៏រៀបចំឲ្យស្រេចបាច់ទៅ ថ្ងៃស្អែកនេះ ជាថ្ងៃមានភ្លៀងធំ ឯអ្នកស្រុកក៏ជឿតាមត្រឡប់ទៅផ្ទះវិញ បានហាមប្រាមគ្នីគ្នាអស់ទាំងស្រុក លុះថ្ងៃស្អែកឡើងភ្លៀងក៏ធ្លាក់មកមែន ដូចពាក្យលោកតាសួសទាយ ឯ

អ្នកស្រុកក៏រឹតតែជឿហើយជឿទៀត ជឿនោះពុំល្ងាត ជឿអស់ទាំងអ្នកស្រុក ជឿនោះមិនសាប់ ជឿនោះមិនសុខ អស់ទាំងអ្នកស្រុកមកជឿមនុស្សក្លូត ៗ ឈ្មោះលោកតាសួស ក៏ឮល្បីល្បាញដល់ព្រះរាជាដែលសោយរាជ្យក្នុងព្រះនគរ ព្រះរាជាចង់ដឹងមន្តវិជ្ជាការលោកតាសួសនោះដែរ ៗ

ចួនជាពេលនោះ ព្រះរាជាបាត់ប្រាក់ជាច្រើន ប្រហែលជាពីរការុងអង្គរ ឯប្រាក់នោះ គឺអាមាត្យម្នាក់ឈ្មោះ (អាប្រាណ) វាលួចយកទៅលាក់ ព្រះរាជាទ្រង់ចាត់អាមាត្យម្នាក់ឲ្យមកនិមន្តលោកតាសួសយកទៅដើម្បីទំនាយឲ្យឃើញប្រាក់ អាមាត្យបាននិមន្តលោកតាសួសយកទៅតាមបង្គាប់ ដល់ហើយ ព្រះរាជានិមន្តលោកតាសួសឲ្យចូលទៅក្នុងបន្ទប់ ១ យ៉ាងស្ងាត់ ប្រគេនចង្ហាន់ធាន់ស្រួលបួលចាំដល់ពេលល្ងាច ទើបនិមន្តលោកឲ្យទំនាយ ឯតាសួសមានសេចក្តីភិតភ័យខ្លាំងលើសមុន គិតថាឱ! អញស្លាប់រស់ក្នុងពេលនេះហើយមើលទៅ គិត ១ គិត ២ ក៏នៅតែពុំទាន់ជាប់ស្រេច ឯអាមាត្យម្នាក់ឈ្មោះអាប្រាណនោះ វាដើរក្រឡឹងចុះក្រឡឹងឡើងព្រោះវាភ័យខ្លាំងណាស់ គិតនឹងចូលមករកលោកតាសួសឲ្យជួយវា កុំឲ្យទាយចំឈ្មោះវា តែបើចំឈ្មោះអញៗ មុខជាស្លាប់ក្នុងពេលនេះមិនខានអាប្រាណនោះវាមិនទៅណាឆ្ងាយពីលោកតាសួសសោះ ព្រោះវាប្រុង

អែបដើរនឹងតាសួស ឯតាសួសគិតសព្វគ្រប់ទៅមិនដឹងជាទៅផ្លូវណា ទើបបញ្ចេញវាចាថា ៖

ហើយចុះ អាខ្លួនប្រាណ មួយប៉ុណ្ណេះស្ដាយណាស់ក្អើអ្អី បើស្លាប់ក៏ស្លាប់ទៅចុះ តាមយថាកម្មអញ ឯអាប្រាណ បានត្រូវជ្រោះ ស្លាប់ពុំបាន ត្រង់ខ្លួនត្រូវតែត្រង់ប្រាណមួយម្នាក់ប៉ុណ្ណោះ ក៏នឹកស្មានថាអញស្លាប់មើលទៅព្រោះលោកតាសួសថា អាប្រាណ ស្លាប់ក៏ស្លាប់ទៅចុះនេះពិតជាឈ្មោះអញក៏យំខ្លាំងណាស់ ទើបចូលទៅក្រាបក្រោមបាទាលោកតាសួស អង្វរករថាកុំឲ្យតែបញ្ចេញឈ្មោះខ្ញុំករុណាថាលួចប្រាក់ ឯតាសួសបានពិតប្រាកដថាឈ្មោះអាប្រាណលួចយកប្រាក់ទៅ ៗ លុះដល់ពេលល្ងាចព្រះរាជានិមន្តតាសួស ៗ ក៏ចាប់យកដីសនឹងគូរឈូនពីក្នុងបង់យាម មកគូសខ្វែងចុះឡើង ហើយរាប់តាមលេខថា:

ប៉ុតអ៊ិតប៉ុតអ៊ី ដើរតាមប្រាំបី
បេកផុតដំឡូងស្បោវ . . . .
អត្តខ្លួនប្រាណ ប្រាក់បាត់ពុំបាន
នៅក្នុងទីនេះ . . . . .
អត្តខ្លួនហើយនឹងប្រាណ
ទៅណាពុំបាន នៅលើអាប្រាណ ៗ

រួចហើយតាសួសសួរព្រះពជា ថា ៖

បពិត្រមហាពជ អាមាត្យព្រះអង្គមានឈ្មោះអាប្រាណដែរឬទេ ?

— ករុណា ម្ចាស់មាន

— បើដូច្នោះ ព្រះមហាពជគ្មានទៅណាទេ មុខជាឈ្មោះអាប្រាណវាលួចយកទៅ ព្រះពជាព្ធ ហើយ បានឲ្យពេជ្ឈឃាតចាប់យកខ្លួនអាប្រាណមកសួររកប្រាក់ទាល់តែឃើញមែន ទើបឲ្យពេជ្ឈឃាតនាំយកអាប្រាណទៅសម្លាប់ចោលទៅ ។ ទ្រង់ពោលសរសើរលោកតាសួស



ថាចេះទាយត្រូវមែន ទើបព្រះពជាទ្រង់ប្រគេនប្រាក់មួយការុង ទៅលោកតាសួស ។

ព្រះរាជាសួរទៀតថា ៖

ចុះលេខទាយព្រះគុណម្ចាស់រាប់ថាប៉ាក់ស៊ិកប៉ាក់ស៊ីដូច្នេះមែនឬ ?

– ថ្វាយព្រះពរលេខអាត្មាភាពយ៉ាងហ្នឹងមែន

– បើយ៉ាងហ្នឹងមែន ព្រះករុណាសូមថ្វាយព្រះនាមដល់ព្រះគុណម្ចាស់ ប៉ាក់ស៊ិកប៉ាក់ស៊ីទៅវិញ ដើម្បីឲ្យងាយចំណាំចាំបានទៅថ្ងៃមុខថ្ងៃក្រោយទៀត , មែនពិតកាលពីដើមឈ្មោះ លោកគ្រូប៉ាក់ស៊ិកប៉ាក់ស៊ីទេ លុះយូរមកទើបក្លាយមកគេហៅថា លោកគ្រូស៊ិកស៊ីជាប់មកដល់សព្វថ្ងៃនេះ ៗ រួចហើយលោកគ្រូស៊ិកស៊ីក៏ថ្វាយព្រះពរព្រះរាជាវិលត្រឡប់មកកាន់ទីលំនៅវិញ ; លុះនៅយូរមកលោកគ្រូស៊ិកស៊ីរកស៊ីចិញ្ចឹមជីវិតបែបនេះជារាងរាល់ឆ្នាំ ដរាបដល់ខ្លួនលោកចាស់ទ្រុឌទ្រោមគ្រាំគ្រា បន្តិចមក ក៏គិតឧបាយមួយផ្សេងពីនោះ ថាអាត្មាអញបើរកស៊ីចិញ្ចឹមជីវិតបែបនេះ មុខជាមហន្តរាយណាមួយមកនាំខ្លួនអាត្មាអញទៅឲ្យសោយសេចក្ដីទុក្ខលំបាកមិនខាន ណ្ហើយបើដូច្នេះអាត្មាអញតាំងចិត្តផ្ដាច់បង់នូវអំពើជាអកុសលទាំងនេះចេញ កិរិយាបែបនេះមុខជាពុំបានសុខទេ ធម្មតាអ្នកដើរកួតករកុហកគេ មិនដែលបានសុខបានចំរើនទេ ពិតប្រាកដជាប៉ះពាទៅលើទុក្ខណាមួយមានប៉ះប៉ៅលើសេចក្ដីទុក្ខលំបាក ស្មើរតែស្លាប់ក៏សឹងមានដែរ សមដូចពាក្យបុរាណលោកពោលថា ៖

លួចគេក៏គ្រាន់ តែគេទាន់មុខជាក្រែល ...

ពេលខាងក្រោយមក លោកគ្រូអ៊ិកអ៊ី បានឮពួកក្មេងអ្នកស្រុកជាប់បបួលគ្នា ច្រៀងលេងថា ៖

ពុំកួនផួនមីលាន់ លួចគេក៏គ្រាន់
តែគេទាន់ក៏ក្រែល .....
ពុំកួនផួនមីលាន់ កួតគេក៏គ្រាន់
គេដេញទាន់ក៏ក្រែល .....
ពុំកួនផួនមីលាប់ បើកួតពុំគាប់
វិនាសខ្លួនប្រាណ ..... ៗ

លោកគ្រូអ៊ិកអ៊ី ឮពាក្យនោះហើយ មានចិត្តត្រេកអរបន្តិច ទោមនស្សបន្តិច គិតទៅថ្ងៃមុខថ្ងៃក្រោយ រួចហើយបែរទៅជាយំសោក យំសោករួចហើយបែទៅជាសើចសប្បាយតែម្នាក់ឯងទៅវិញ ពេលដែលសើចសប្បាយ ព្រោះនឹកឃើញថា បើអញកួតគេនោះជួនជាគាប់ ពេលដែលយំសោកព្រោះនឹកឃើញថា បើអញកួតគេទៅជួនជាពុំគាប់ មុខជាជាប់ទោសទាំងក្នុងលោកនេះ នឹងលោកខាងមុខ ទោសធ្ងន់ណាស់ ! ហើយខ្លួនអញជាសង្ឃផងពុំគួរសោះ !!

លោកគ្រូអ៊ិកអ៊ី គិតឃើញដូច្នោះ ក៏លះបង់អំពើកួតករចេញតាំងពីពេល

នោះមកព្រមទាំងកូនសិស្ស ៣ នាក់ ក៏ធ្វើដូចគ្នា ចិញ្ចឹមជីវិតតាមសម្មាជីវភាពរៀងៗខ្លួន រហូតមក ។ រឿងរ៉ាវនេះ អស់សេចក្ដីតែប៉ុណ្ណោះឯង ។

កវី សុខ - បឿ

រៀបរៀង

សៀវភៅប្រលោមលោកតែងដោយ

# អ្នកស្រី ស៊ុយ.ហៀង

## មានបោះពុម្ពផ្សាយហើយ

១ - វាសនានៃនាងណាគ្រី — តម្លៃ ១ ក្បាល ១២រ

២ - ស្ទឹងក្រហម ទី ១ និងទី ២ ចប់ — តម្លៃ " ១២រ

៣ - ផ្ការីកផ្ការោយ — តម្លៃ " ១២រ

៤ - ក្លូនក្រកមេចោរ ទី ១ និងទី ២ ចប់ — តម្លៃ " ១៤រ

## បំរុងចេញនៅថ្ងៃក្រោយ

១ - អ្នកណាសម្លាប់នាយមែន ?

២ - វាលខ្សាច់ស

៣ - ពន្លឺប្រទីបក្នុងរូងភ្នំ

៤ - ភ្លើងឆេះនៅចំការចិន

៥ - ថ្នុកឈាមផក់កប់ក្នុងស្រែ

៦ - ស្នេហាគ្មានពិចារណា

# ខេមរបណ្ណាគារ និងរោងពុម្ព

ផ្ទះលេខ ៣ វិថីប៉ែនវូឡង់ហ្សូរ៉ង់ ខាងកើតផ្សារធំថ្មី ភ្នំពេញ សូមថ្វាយប្រគេន ជូនដំណឹង សូមទិញស្រាប តាមស្រាប ស្រាប ៗ

ខេមរបណ្ណាគារ ជាបណ្ណាគាររបស់ខ្មែរតែមួយ ដែលធំជាងគេក្នុងកម្ពុជជាតិ មានសៀវភៅខ្មែរ-បារាំង-អង់គ្លេស ព្រមទាំងប្រដាប់ប្រដាឯទៀតៗ ជាច្រើន សំរាប់គ្រូនិងសិស្សរៀនសូត្រ ឬមើលកំសាន្ត ៗ

សព្វថ្ងៃកំពុងតែបោះពុម្ពផ្សាយ មានរូបភាពផ្សេងៗ និងសៀវភៅច្រើនមុខ ក្នុងមួយខែមានចេញ ៤ រឿងរៀងរាល់ខែ មានលក់ដុំនិងលក់រាយ ផ្ញើជូនគ្រប់ខេត្តគ្រប់ស្រុក ព្រមទាំងទទួលជួលបោះពុម្ពអក្សរ-សាស្ត្រ តាមបំណងលោក-អ្នក គិតថ្លៃថោកគួរសមជូន ៗ

សៀវភៅបោះពុម្ពរួចហើយគឺ.

១– សុភាសិតបារាំង ប្រែជាពាក្យកាព្យខ្មែរ លោកប៉ាយ-ប៊ុក រៀបរៀង ភាគ ១ និងភាគ ២-១ក្បាល ៦៛០០

២– រឿងប្រលោមលោក វិស្សាខែនាងណាគ្រី អ្នកស្រី ស៊ុយ ហៀង រៀបរៀង ១០៛០០

៣– បបញ្ចធម៌ ព្រះមហាទេ-អ៊ុម-ស៊ុម រៀបរៀង ៦៛០០

៤– ចម្រៀង "ឡាំប៊ូគ" និងចម្រៀងសម័យ បោះពុម្ពលើកថ្មី ៨៛០០

៥_ ប្រវត្តិនៃ "មហាត្មគន្ធី" លោក វ៉ាយ-ប៊ុក រៀបរៀង ១៥រ០០

៦_ "ពុទ្ធវិបស្សនាយកឋា" សម្ដេចអំពីប្រជុំនៃពុទ្ធវចនៈវិទ្យុ ធម្មទេសនាគិគុមហា ទ. ឈឹម-ម៉ឺធម្មប្បញ្ញាគោ រៀបរៀង ៥រ០០

៧_ រឿងព្រេងបូរាណផ្សេងៗ ភាគមួយមានរឿងមរណមាតា រឿងវង្ខ, រឿងមនុស្សដីកក្ដាម ៥រ០០ មានភាគ ២ ហើយមានចេញភាគត ១ ទៅទៀតជាលំដាប់

៨_ រឿងនាងបទុមវតី ៦រ០០

៩ _ រឿងប្រលោមលោក "ស្នឹងក្រហម" ជារឿងកំសត់ អ្នកស្រី ស៊ុយ-ហៀង រៀបរៀង ១២រ០០

១០_ រឿងព្រេង "ស្នប៊ិន" ជារឿងព្រេងពាក្យកាព្យ៦រ០០

១១ _ "ធនញ្ជ័យ" ពាក្យកាព្យទី ១ ៦រ០០

១២_ កែវគុណ រឿងព្រេងចិន ទី ១-២ ១០រ០០

១៣- មាយើង ស្រែកឡើងចុះទឹងស្រីគ្រប់លក្ខណ៍ ៧រ០០

១៤- ផ្កាវីកផ្ការោយ អ្នកស្រី ស៊ុយ ហៀង តែង ១២រ០០

១៥- ពុទ្ធទំនាយ ៥រ០០

១៦ – បិនលីគម្ពីរស្វែងរកព្រះបាទធម្មិករាជ ៥,០០

១៧ – ព្រះរាជពង្សាវតារនគរខ្មែរ ១០,០០

១៨– តំណក់ឈាមលើផ្កាកូលាប ១១,០០

*លោក ប៊ីវ-ថៃ លាង រតន*

១៩– រឿងមកុដពេជ្រ លោក ប៊ុំ-ថៃ-លាង ទី ១០,០០

ទី២ ១២,០០

២០– បុណ្យអភិធម្ម នឹង ប្រស្នាអភិធម្ម ១០,០០

២១– រឿងអាឡេវ ៧,០០

២២– រឿងចៅខ្វាក់ចៅខ្វិន ៨,០០

២៣– រឿងលោកគ្រូអ៊ិកអ៊ី

២៤– មេសូត្រសំរាំង (សំរាប់គ្រូនឹងសិស្ស)

២៥– ហាត់អានសម័យនិយម

២៦– និ-សាន ទុគ៌ិត ស៊ិប-ឡុង រៀបរៀង

២៧– Recueil dedictées C.E.P. 12$

២៨– Recueil de problèmes C.E.P 12$

២៩– Recueil de rédactions C.E.P 12$

៣០ – Géographie de l Indochine à paraitre

ពុទ្ធសាសនបណ្ឌិត្យ